សុន្ទរកថារបស់ **ឯកឧត្តម ម៉ាសាហ៊្វូមី គូរ៉ូគី** ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាព
របស់ប្រទេសជប៉ុនប្រចាំកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន

២៥ មិថុនា ២០១២

**សូមគោរព លោក KIMURA Toshio នាយកប្រតិបត្តិអង្គការមូលនិធិជប៉ុន - ភី . អេចស៍**
**សូមគោរព លោកស្រី KUME Yumiko អ្នកតំណាងប្រចាំប្រទេសរបស់អង្គការមូលនិធិជប៉ុន - ភី . អេចស៍**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីចុះហត្ថលេខា នៅថ្ងៃនេះ លើកិច្ចសន្យាផ្តល់ជំនួយជាមួយ អង្គការមូលនិធិជប៉ុន - ភី . អេចស៍ (PHJ) ដែលនឹងអនុវត្តគម្រោងសហគមន៍ថែទាំសុខភាពមូលដ្ឋានសម្រាប់មាតា និងទារក(ដំណាក់កាលទី២) ដែលជាគម្រោងជំនួយសម្រាប់អង្គក្រៅរដ្ឋាភិបាលជប៉ុន។

នៅពេលដែលការផ្តល់ជំនួយក្នុងវិស័យសុខាភិបាល ពិសេសការលើកស្ទួយសុខភាពមាតានិងទារក មានសារៈសំខាន់ក្នុងស្មារតីមនុស្សធម៌នោះ ជំនួយនេះក៏ត្រូវបានវាយតំលៃខ្ពស់ក្នុងផ្នែកសេដ្ឋកិច្ចថាជាការវិនិយោគលើកុមារដែលនឹងក្លាយជាអ្នកដឹកនាំសង្គមជាតិនាពេលអនាគតផងដែរ។ យុទ្ធសាស្ត្រចតុកោណ ដែលជាយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍ជាតិរបស់កម្ពុជាក៏បានបញ្ជាក់យ៉ាងច្បាស់លាស់អំពីកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាដើម្បីលើកស្ទួយស្ថានភាពសុខភាពមាតា និងទារក។ ជាងនេះទៅទៀត ផែនការយុទ្ធសាស្ត្រនៃវិស័យសុខាភិបាលសម្រាប់ឆ្នាំ២០០៨-២០១៥ក៏បានផ្តល់អាទិភាពខ្ពស់ទៅលើការកែលម្អស្ថានភាពសុខភាពមាតា និងទារកផងដែរ។ រដ្ឋាភិបាលជប៉ុនក៏បានរួមចំណែកដល់ការធ្វើឲ្យប្រសើរឡើងនូវការថែទាំសុខភាពមាតា និងទារកនៅកម្ពុជាតាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល និងការអភិវឌ្ឍន៍ធនធានមនុស្ស ចាប់តាំងពីការសាងសង់មជ្ឈមណ្ឌលជាតិគាំពារសុខភាពមាតា និងទារកដោយជំនួយឥតសំណងរបស់ជប៉ុន។

ដោយមានកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាការគាំទ្រពីអ្នកផ្តល់ជំនួយដែលរួមទាំងរដ្ឋាភិបាលជប៉ុនផងនោះ អត្រាមរណៈមាតានិងទារកបាននិងកំពុងមានសភាពប្រសើរឡើងក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ ទោះជាយ៉ាងណាក៏ដោយ បើប្រៀបធៀបទៅនឹងប្រទេសជិតខាង កម្ពុជានៅតែមានកម្រិតខ្ពស់នៅឡើយ ហើយយើងចាំបាច់ត្រូវធ្វើការកែលម្អស្ថានភាពសុខភាពមាតានិងទារក ជាពិសេសនៅតំបន់ជនបទ។ ក្នុងបរិបទនេះ អង្គការក្រៅរដ្ឋាភិបាលជាច្រើនកំពុងធ្វើកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ ខិតខំប្រឹងប្រែងជួយបង្គ្រប់គ្នាទៅវិញទៅមកដើម្បីកែលម្អធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពមាតា និងទារកនៅកម្ពុជា។

តាមរយៈជំនួយឧបត្ថម្ភសម្រាប់អង្គការក្រៅរដ្ឋាភិបាលជប៉ុននេះ PHJបានអនុវត្តសកម្មភាពដែលមានគោលដៅលើកកម្ពស់ស្ថានភាពសុខភាពមាតា និងទារកនៅស្រុកប្រតិបត្តិបារាយណ៍-សន្ទុកដែលជាស្រុកជនបទមួយនៅប៉ែកខាងត្បូងខេត្តកំពង់ធំ។ PHJបានជួយជួសជុលមណ្ឌលសុខភាពជាច្រើន ផ្តល់វគ្គបណ្តុះបណ្តាលដល់ឆ្មប បុគ្គលិកមណ្ឌលសុខភាព និងអ្នកស្ម័គ្រចិត្តសុខាភិបាល ក៏ដូចជាការអប់រំអំពីការថែទាំសុខភាពមាតានិងទារកដល់ប្រជាជនក្នុងតំបន់គោលដៅ និងបង្កើតស្នាដៃជាបន្តបន្ទាប់។ ជាលទ្ធផល យើងបានទទួលដំណឹងថាចំនួនប្រជាជនដែលទទួលបានសេវាថែទាំសុខភាពមាតា និងទារកដូចជាការសម្រាលកូននៅមណ្ឌលសុខភាពដែលមានជំនួយពីឆ្មបជំនាញ និងការពិនិត្យផ្ទៃពោះមុនសម្រាលបានកើនឡើង ហើយការផ្លាស់ប្តូរផ្នត់គំនិត និងសកម្មភាពរបស់ប្រជាជនចំពោះសុខភាពមាតា និងទារកក៏បានក្លាយជាទង្វើជាក់ស្តែង។

គម្រោងថ្មីសម្រាប់ឆ្នាំនេះគឺជាដំណាក់កាលទី២បន្តពីគម្រោងឆ្នាំមុនដែលនឹងបន្តសកម្មភាពកែលម្អបន្ថែមទៀត។ តាមរយៈគម្រោងនេះ យើងសង្ឃឹមថាប្រជាពលរដ្ឋក្នុងតំបន់ប្រមាណ៤៧,០០០នាក់នឹងទទួលបានចំណេះដឹងផ្នែកសុខភាពមាតា និងទារក និងផ្នែកអនាម័យកាន់តែប្រសើរឡើង ព្រមទាំងអាចប្រើប្រាស់ធនធាននៅក្នុងតំបន់ដើម្បីរស់នៅប្រកបដោយសុខភាព និងអនាម័យ។

ជាចុងក្រោយនេះ ជំនួយសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុននេះគឺដើម្បីគាំទ្រដល់គម្រោងអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចដែលផ្តល់ប្រយោជន៍ដោយផ្ទាល់ដល់ប្រជាជននៅថ្នាក់មូលដ្ឋាន។ ខ្ញុំសូមជូនពរសូមឲ្យគម្រោងនេះអាចអនុវត្តទៅដោយរលូន ហើយខ្ញុំសង្ឃឹមថាគម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណ!